ខ្ញុំមិនដែល.......ដឹងថា......ដឹងថានឹងមានអារម្មណ៍យ៉ាងណាទេ នៅពេលដែលមាននរណាម្នាក់ចង់ឱ្យយើងនៅក្បែរគេ!

«ក្លាយមកជារបស់អ្នកណាម្នាក់....» គឺជាពាក្យដែលខ្ញុំកម្រគិតដល់ណាស់ ទោះជាយ៉ាងណា គេម្នាក់នេះហាក់បាននិយាយចេញយ៉ាងងាយស្រួល ដូចជាគ្មានចាំបាច់គិតច្រើនអ្វីសោះ។

«ចង់ឃើញ...?»

គេខ្សឹបបញ្ឆោក់មកខ្ញុំហើយខ្ញុំមិនទាន់មានប្រតិកម្មផង ស្រាប់តែបបូរមាត់របស់គេឱនមកសង្កត់លើមាត់ខ្ញុំ

«...មានអារម្មណ៍យ៉ាងណាពេលក្លាយជារបស់ខ្ញុំ?»

គេឡុលៗមកទាំងដែលមាត់យើងប៉ះគ្នា។ កម្ដៅផ្ទុះឡើងនៅកន្លែងណាមួយក្នុងក្រលៀនរបស់ខ្ញុំ នៅក្នុងទ្រូង ពោះ និងបេះដូង.....គ្រប់កន្លែងដែលមិនធ្លាប់បានរំញោច។

កម្ដៅរត់ពេញ.....ជាកម្ដៅរាងកាយដែលចម្លងមកតាមការថើបរបស់គេ។ កម្ដៅដដែលនោះបានសាយភាយពេញដៃជើង ដាស់អារម្មណ៍ទាំងអស់របស់ខ្ញុំ ធ្វើឱ្យសរសៃប្រសាទរបស់ខ្ញុំទាំងអស់ស្ពឹក ចលនាហាក់មានភាពរអាក់រអួលជាមួយនឹងការរំពឹងថា សំងំចាំបន្តិច ចង់ដឹងណាស់.....នឹងមានអ្វីកើតឡើងបន្ទាប់ទៀត។

បបូរមាត់របស់គាត់កំពុងចោលដង្ហើមមកលើខ្ញុំយ៉ាងស្រទន់។ អណ្តាតរបស់ខ្ញុំ រលោមចង់លូកចេញចូលទៅឆ្លើយតបក្នុងមាត់ប្រុសស្អាត ប៉ុន្តែខ្ញុំនៅអាចទប់អារម្មណ៍ខ្លួនបានខណៈដែលម្រាមដៃរបស់គាត់ឃឹតៗឡើងមកសន្សឹមតាមបន្ទាត់ពួរពីកែងដៃរបស់ខ្ញុំរហូតដល់ស្មា។

ខ្ញុំមិនដែលដឹងថាខ្ញុំមានសរសៃប្រសាទភ្ញោចងាយច្រើនបែបនេះទេ។ ពេលនេះទើបទទួលស្គាល់ថា ខ្ញុំអាចមានអារម្មណ៍រីករាយជាខ្លាំងថែមរន្ធត់លាយឡំគ្នាពីកន្លែងអស់ទាំងនោះ។

ប្រហែលជា វាមិនមែនជាកន្លែងដែលខ្ញុំកំពុងត្រូវបានប៉ះពាល់ តែជាការចម្លងមកពីអ្នកដែលកំពុងប៉ះពាល់ខ្ញុំ ឯខ្ញុំ.....មានតែត្រូវការបន្ថែមទៀត....ច្រើនទៀត។

ការសម្រេចចិត្តនេះបានបន្លឺឡើងនៅក្នុងចិត្តរបស់ខ្ញុំ ដូចជាសំឡេងជួងព្រះវិហាររាប់លានអន្លូងដែលទាមទារឱ្យព្ទ ដើម្បីទទួលស្គាល់។

ខ្ញុំចង់ឱ្យគាត់ថើបខ្ញុំ ស្និទ្ធទៀត ជ្រៅជាងនេះ និងប៉ះខ្ញុំគ្រប់កន្លែងដែលមិនធ្លាប់មានអ្នកណាពីមុនមក។

«Bianca?»

ខ្ញុំចង់ឱ្យគេហៅឈ្មោះខ្ញុំ ប៉ុន្តែបែរមិនមែនជាសំឡេងគេសោះ។

ក្នុងទិសដៅដំបូង ខ្ញុំឃើញមិត្តរបស់ខ្ញុំ។ មិត្តជិតដិតតែមួយគត់របស់ខ្ញុំ។ នាងមើលមកខ្ញុំ ភ័យ និងឆ្ងល់។ បន្ទាប់មក ខ្ញុំអាចមើលឃើញគ្រប់យ៉ាងដោយភាពតក់ស្លុត គឺខ្ញុំកំពុងដេកមិនមែននៅក្នុងព្រៃឋានសួគ៌ទេ។

រ៉ូសញញឹមដាក់ខ្ញុំហើយដកខ្លួនថយ។ ខ្មាសណាស់ តើខ្ញុំមានច្រឡំរោលរាលដាក់រ៉ូស?

មួយសន្ទុះក្រោយមកពេលខ្ញុំឆុងកាហ្វេមកកាន់ រ៉ូសក៏បង្ហាញខ្លួនពីក្រោយខ្ញុំ។

«មិនអីទេ?» Rose សួរខ្ញុំ។

សំឡេងរបស់នាងតែងតែស្តាប់ទៅដូចជានាងអាយុ១៨ឆ្នាំ ហើយថ្ពាល់ក្រហមរបស់នាងធ្វើឱ្យមើលទៅក្មេងជាងខ្ញុំឆ្ងាយ ទោះបីជាពួកយើងមានអាយុដំណាលគ្នាក៏ដោយ។ នោះគឺជារឿងមួយដែលតែងតែធ្វើឱ្យយើងជិតស្និទ្ធ។

ចំណែកការពិតគួរឱ្យអាណិតរបស់រ៉ូសគឺ  នាងជាទារយាទនៃអម្បូរអ្នកបន្តវេន ដែលត្រូវបានក្រុមអម្បូរផ្សេងទុកថាអាចជាសត្រូវ ហើយនិងតាមសម្លុតយាយីដោយនាងបិសាចGala និងបក្សពួក។

«ខ្ញុំមានអីឯណា?» ខ្ញុំធានាជាមួយរ៉ូសហើយដកថយមកផ្សើមបំពង់កជាមួយជាតិល្វីងឈ្មុយ។

«យល់សប្តិឃើញប្រុសស្អាត?» Roseសួរឱមកហើយសើច។

«នរណា??»

«បុរសម្នាក់! ឯងហៅគេថា លោក!!!»

ដកដង្ហើមធំ រួចបែរមករកនាងវិញ។

«ត្រូវ!!! ខ្ញុំសុបិនឃើញប្រុសម្នាក់ដែលបានជួយខ្ញុំកាលពីយប់មិញ នៅពេលដែលពួកGalaចាប់! តែ....គេមិនមែនប្រុសស្អាតទេ.....មុខគេមានសម្លាក!»

«បិសាចជញ្ជក់ឈាមជួយឯង?»

ទីបំផុត Roseបង្ហាញចេញពីមូលហេតុនៃការភ្ញាក់ផ្អើលរបស់នាងហើយ នាងមិនមែនចំអន់ខ្ញុំ តែនាងជាអម្បូរបន្តវេន នាងស្គាល់ក្លិនអម្បូរមិនមែនមនុស្សគ្រប់អម្បូរ។

ថ្គាមរបស់ខ្ញុំស្ទើរតែធ្លាក់សំយ៉ុងព្រោះខកចិត្ត។

«បិសាចជញ្ជក់ឈាម?»

Roseមិននិយាយអ្វីទៀតនៅឡើយ។ ពាក្យពិតប្រហែលជាស្ថិតសំងំនៅក្នុងចន្លោះទទេរវាងពីរនាក់យើង ដូចជាគ្រាប់បែកម៉ោងប្រុងផ្ទុះ។

ទីបំផុតខ្ញុំ នៅតែមិនអាចកាត់ចិត្តថាមិនសួរ។ ខ្ញុំសួរបញ្ជាក់៖

«គាត់ជាបិសាចជញ្ជក់ឈាមមែនទេ?»

«ហើយ....មិនមែនត្រឹមតែជាបិសាចជញ្ជក់ឈាមធម្មតាៗទេ Bianca»

Roseប្រាប់ខ្ញុំដោយស្ដាប់ទៅ សំឡេងនាងដូចជាបារម្ភជាងពេលណាទាំងអស់។

«ឯង....ចង់មានន័យថា.....?» ខ្ញុំសួរសើៗភ័យៗ។

«ក្លិនគេ ជា...ជាស្ដេចបិសាច!»

ដំបូងខ្ញុំគិតថានាងនិយាយលេង។ ស្ដេចបិសាច? ធ្លាប់មានឯកសារព្រឹទ្ធបុរសខ្លះសរសេរទុកមកថា មិនមានបិសាចជញ្ជក់ឈាមនៅមួយជុំទីក្រុងនេះ រយៈពេលជាច្រើនទសវត្សរ៍មកហើយ។ ម្យ៉ាងទៀតថា អាមេរិកក៏មានត្រកូលបិសាចហោចតិចទៅៗដោយស្ដេចជាអ្នកដឹកនាំបន្តតែងត្រូវបានប៉ូលិសតាមប្រមាញ់សម្លាប់។

«ប្រាកដឬអត់?» ខ្ញុំសួរទាំងសម្លឹងនាងម៉ក់ៗ។

Rose ពន្យល់ខ្ញុំភ្លាមថា៖

«បិសាចជញ្ជក់ឈាម ធម្មតាមានក្លិនក្រអូបតិចជាងនេះ! អូខេ ដឹងថាឯងមិនអាចធុំក្លិនពួកគេបានទេព្រោះឯងជាមនុស្ស ប៉ុន្តែជឿខ្ញុំ ស្ដេចបិសាចគឺជារឿងធំ! ខ្ញុំធុំក្លិនគេភ្លាមៗ សូម្បីមិនដែលចួបគេគ្រាន់តែបេះដូងឯងរំពឹកពីគេដោយភាពស្មោះត្រង់ ខ្ញុំក៏ដឹង.....ដោយញាណវេទមន្ត!»

ប្រហែលជា....ខ្ញុំគ្មានអ្វីត្រូវតវ៉ាទេ។ រ៉ូសទៀងត្រង់ហើយមានញាណពិសេសពិតមែន។ រឿងនេះ យើងរាល់គ្នាដឹងមកយូរហើយ។

«យើងត្រូវប្រាប់អ្នករាល់គ្នាឱ្យប្រុងប្រយ័ត្នទេ?»

«ទេ!» ខ្ញុំស្រែកបន្ទាន់ឃាត់នាងភ្លាម ធ្វើឱ្យរ៉ូសសម្លឹងមកខ្ញុំយ៉ាងភ្ញាក់ផ្អើល។

«ឯងចង់មានន័យថាម៉េច?» រ៉ូសនាងសម្លុតខ្សឹបៗសួរខ្ញុំ ហើយសង្កត់ពាក្យ៖ «យើងត្រូវប្រាប់អ្នកបន្តវេនផ្សេងៗទៀតឱ្យគិតគួរអំពីសុវត្ថិភាពព្រោះថាមានមេបិសាចមកដល់ទីក្រុងនេះ»

នាងនិយាយត្រូវ មិនមែនខ្ញុំមិនដឹងទេ ថាវានឹងក្លាយជាអ្វីមួយដែលត្រូវបានរំពឹងទុកថាអាក្រក់ច្រើនជាងសំណាង។ តែ.....

«កុំទាន់ប្រកាសប្រាប់គេរាល់គ្នាណា Rose» ខ្ញុំអង្វរនាង ។ នាងបើកភ្នែកធំៗ ខ្ញុំអង្វរទៀត៖

«សុំ.....គ្រាន់តែពន្យារពេលមួយថ្ងៃឬពីរថ្ងៃសិនណា៎!»

«ឯង?»

«សូមអង្វរ! គេមានគុណលើជីវិតខ្ញុំ!!»

នាងសម្លឹងខ្ញុំហាក់មិនគួរឱ្យជឿនិងហាក់ដូចជាមិនយល់ថា ហេតុអ្វីបានជាខ្ញុំចិត្តទន់នឹងសភាពការណ៍គ្រោះថ្នាក់បែបនេះ។

អ្ហើយ ខ្ញុំផ្ទាល់ក៏មិនដឹងផងថា ហេតុអ្វីបានជាខ្ញុំហ៊ានគិតពីគេ ទាំងមិនដឹងផងថាគេនឹងនាំមកនូវគ្រោះថ្នាក់អ្វីខ្លះដល់ពួកយើង។

អ្វីដែលខ្ញុំដឹងក្នុងបេះដូង គឺខ្ញុំជំពាក់គុណគេ។

ប៉ុណ្ណឹង!!!

«ពីរថ្ងៃ!» បញ្ជាក់ដោយញាក់ចិញ្ចើមខឹងមុខស្មើ។

ខ្ញុំងក់ក្បាលដោយអំណរគុណ តែRoseគ្រវីក្បាលខឹងដាក់ខ្ញុំ។ មុនចាកចេញនាងឆ្លៀតព្រមានខ្ញុំ៖

«ខ្ញុំសង្ឃឹមថា ឯងដឹងថាខ្លួនឯងកំពុងធ្វើអ្វី គិតអ្វី Bianca!»

ខ្ញុំងក់ក្បាល ប៉ុន្តែការពិត គឺ....ខ្ញុំវិលហើយ.....ខ្ញុំមិនដឹងចិត្តខ្លួនឯងច្បាស់ទេ។

# សត្វក្នុងខ្លួនខ្ញុំ-អេដមុន

ពេញមួយថ្ងៃហើយ សត្វបានៅក្នុងខ្លួនខ្ញុំនៅមិនស្រួលដែរទេ វាកញ្ច្រោលចង់ចួបនាងម្តងទៀត ។ ជាសភាវគតិ ខ្ញុំនិងនាងមានអ្វីមួយ.....ពាក់ព័ន្ធគ្នា។

Kano ចង់តាមការពារខ្ញុំ ដោយចង់ចូលទីក្រុងជាមួយខ្ញុំសម្រាប់បេសកកម្មស្វែងរកអណ្តូង ពេលយប់របស់យើង ប៉ុន្តែខ្ញុំបានប្រាប់គេឱ្យចូលរួមជាមួយគូដទៃទៀត។

កាណូ មិនចូលចិត្តឃើញខ្ញុំទៅណាតែម្នាក់ឯងទេ ប៉ុន្តែខ្ញុំមិនចង់មានគេហែហមច្រើន។ ធ្វើដូច្នោះ ខ្ញុំអាចតាមប្រមាញ់ក្លិនរបស់នាងយ៉ាងងាយស្រួលនិងអាថ៌កំបាំង។

កណ្តាលយប់រំលងអាធ្រាត្រហើយ មនុស្សម្នាទាំងអស់កំពុងដេកលក់។ ខ្ញុំដឹងថា មិនអាចប្រហែសបានដដែល ព្រោះនៅតែមានលទ្ធភាពដែលក្រុមអម្បូរផ្សេងមានអ្នកបន្តវេនដែលមានញាណវេទមន្ត អាចដឹងអំពីវត្តមានខ្ញុំ ការមកនៅក្នុងទីក្រុងនេះ។

ពេលនេះ នឹកនាងណាស់ ហើយខ្ញុំមិនចង់បានការរំខាន បានជាប្រចុយប្រចានមកម្នាក់ឯង។ គោលដៅជាផ្ទះមួយនៅជាយក្រុង។ មើលពីឆ្ងាយទៅ ទ្រុឌទ្រោម ស្ទើរតែសម្គាល់បានថា ជាយូរមកហើយគ្មានអ្នករស់នៅទីនោះទេ ប៉ុន្តែខ្ញុំបានឃើញពន្លឺតូចមួយភ្លឺផ្លុងៗនៅបង្អួចជាន់លើ។

ខ្ញុំឆ្ពោះទៅដល់មុខទ្វារទាំងចិត្តមួយបដិសេធថា ខ្ញុំនេះគួរតែត្រលប់ទៅរកKano ហើយចូលរួមបេសកកម្មទឹកអណ្តូង ជាជាងមកនៅទីនេះព្រោះនឹកនាង។

តើខ្ញុំកំពុងធ្វើអ្វីនៅទីនេះ?

ខ្ញុំចាប់ម្រាមដៃច្បូតតាមជួរជើងសក់ខ្លួនឯងទាំងស្មុគចិត្តជាខ្លាំង។ ជាលើកដំបូង ដែលខ្ញុំមានអារម្មណ៍ថាទាក់ទាញខ្លាំងដោយអ្នកណាម្នាក់។ ខ្ញុំធ្លាប់ចួបអម្បូរបិសាចជាស្រីក្រមុំ៩នាក់។ ខ្ញុំបានទៅយកពួកគេពីគ្រែគេងហើយយើងបានត្រេកត្រអាលជាមួយគ្នា...ហើយពួកគេក៏ពេញចិត្តខ្ញុំ.... ទោះជាយ៉ាងនេះក្តី អារម្មណ៍នៃការឃើញមនុស្សស្រីដ៏ផ្អែមល្ហែមម្នាក់នោះ ធ្វើឱ្យខ្ញុំចេះស្គាល់នូវសេចក្តីប្រាថ្នាចង់បានមួយប្រភេទ ដែលច្រើនជាងចំណង់រួមភេទ។ វាកំពុងនាំខ្ញុំឱ្យឆ្កួត។

ខ្ញុំសសៀរនិងរកឃើញបង្អួចដែលរបើកស្រាប់ ហើយតោងវារចូលទៅក្នុងដូចជាចោរ។ អត់ដឹងដែរថា...តើខ្ញុំនៅទីនេះដើម្បីលួចអ្វី?

ខ្ញុំស្ដាប់ដោយយកចិត្តទុកដាក់។ គ្រប់យ៉ាងលង់លក់ក្រោមអំណាចនៃរាត្រីកាលហើយ។ នាងក៏ប្រហែលជាកំពុងគេងដែរ។

ខ្ញុំឆ្ពោះទៅជណ្ដើរ។

«អ្នកណានៅ?»

សំឡេងនាង!!! បេះដូងខ្ញុំចាប់ផ្ដើមលោតញាប់

«អ្ហ៎ា» ខ្ញុំរអ៊ូដាក់ខ្លួនឯងហើយឈប់ជើងភ្លាម។

មើលទៅប្រភពនៃសំឡេង ទីនោះមានទ្វារមួយបើកចំហដែលមានពន្លឺចាំងចុះមកតាមជណ្ដើរផ្លូវចូល។

ខ្ញុំឮស្នូរជើងនាងឈានមកយឺតៗ។ ជាជំហានដែលមានការប្រុងប្រយ័ត្ន ប៉ុន្តែនាងពិតជាកំពុងដើរមករកខ្ញុំ។ ក្លិននាង.....ខ្ញុំឈប់គិតពីរឿងលាក់ខ្លួន។

«លោក.....គឺ.....កំពុងធ្វើអ្វីនៅទីនេះ?»

ខ្ញុំស្ទើរតែនិយាយតបថា៖

«ខ្ញុំគ្រាន់តែតាមមក ព្រោះចង់ធ្វើឱ្យប្រាកដថា នាងនឹងមិនអីទេ»ប៉ុន្តែគតិប្រាប់ថា នោះជាការឆ្លើយតបដ៏ល្ងង់ខ្លៅ។ ខ្ញុំដឹងថា ហេតុអ្វីបានជាខ្ញុំសុខៗមកដល់ទីនេះ ប៉ុន្តែមាត់ខ្ញុំមិនអាចសារភាពចេញមកបាន។

«ធ្វើឱ្យអ្នកភ្ញាក់ផ្អើលទេ?»

នាងមិនឆ្លើយ តែនាងឈរភាំង។

ខ្ញុំឈានទៅជិត នាងក៏មិនគេចទៅណា។ ខ្ញុំវក់ចិត្តនឹងសម្រស់កណ្ដាលរាត្រីកាលរបស់នាង។ មនុស្សក្រអូបម្នាក់នេះ ពាក់អាវយឺតធំដែលធ្លាក់គ្រប់មកដល់កណ្ដាលគល់ភ្លៅ។ ពេលនាងរត់ចុះមកតាមជណ្ដើរ អាវនេះវាហើរជុំវិញជើងនាង។ ដើមទ្រូងរបស់នាងបានរីកឡើងក្រោមក្រណាត់ស្ដើង ក្បាលសុដន់របស់នាងមានអំនួត ស្ទើរតែទម្លុះតាមអាវយឺត។

ខ្ញុំស្រែកថ្ងូរ កម្ទាត់សត្វបាដែលឡើងកក្នុងខ្លួនខ្ញុំជាសម្ងាត់។

«លោកមិនមែនមកសម្លាប់ខ្ញុំទេ?» ស្រាប់តែនាងសួរឡើង ស្ដាប់ទៅដូចជាធ្ងន់ធ្ងរជាងពេលណាទាំងអស់។

«សម្លាប់?» ខ្ញុំសើច «ដើម្បីអី?»

«លោកជា.....ស្ដេចបិសាច!»

នាងដឹងហើយ! ខ្ញុំងក់ក្បាលជាច្រើនដងហើយរេភ្នែកមើលកជុំវិញ ខ្ញុំនិយាយ៖

«មានអ្នកណាម្នាក់ជាអម្បូរបន្តវេន ហើយដឹងរឿងខ្ញុំ ប្រាប់អ្នកអំពីខ្ញុំ?»

នាងលេបទឹកមាត់ភ័យ ដើរថយក្រោយបន្តិច។ ចំណែកខ្ញុំវិញ វត្តមានខ្ញុំដែលត្រូវបានគេគ្រប់គ្នាដឹង សឹងជាហានិភ័យស្រាប់ហើយ។ ពួកគេអាចដាក់អន្ទាក់ធ្វើគត់ខ្ញុំ ដែលនៅឯកោគ្មានបរិវា ម្ដេចខ្ញុំមិនប្រញិបប្រញាប់ចាកចេញ?

ខ្ញុំសុខចិត្តទទួលយកថា ការបារម្ភអំពីសុវត្ថិភាពនៅតែតិចជាងការចង់ឃើញនាង ចង់ប៉ះនាង។ ប្រហែលជាខ្ញុំអាចវាយពួកគេពីរបីនាក់ ហើយរត់ត្រលប់ទៅព្រៃវិញប្រសិនពួកនោះបើកការវាយប្រហារ។

«ទៅវិញទៅ» នាងតឿនខ្សឹប។ នាងមានភាសានៃការបារម្ភមួយយ៉ាងពិសេស ដែលធ្វើឱ្យខ្ញុំកើតសេចក្ដីមានះចង់តែបន្តដំអក់នៅទៅវិញ។

ខ្ញុំចង់ធ្វើជាមនុស្សមិនខ្លាចអ្វីទាំងអស់នៅចំពោះមុខស្រីម្នាក់នេះ។ ដោយប្រមូលគំនិតរបស់ខ្ញុំស្រូបចូលយ៉ាងជ្រៅនូវក្លិនក្រអូបរបស់នាងឱ្យអណ្ដែតចូលមកតាមរន្ធច្រមុះទាំងសងខាង។

«លោកកុំនៅទីនេះទៀត! ទីក្រុងនេះ!»

នាងខ្សឹប។ គ្មានអ្នកណាល្អបែបនេះជាមួយខ្ញុំនោះទេក្រៅពីកូនចៅខ្ញុំ។

«ហេតុអ្វី?» ខ្ញុំគ្រញែងស្មាសួរនាងយឺតៗ។

នាងទីទើរបន្តិច ទើបបានរកនឹកពាក្យមកឆ្លើយបន្តឡើងថា៖

«លោកបានសង្គ្រោះខ្ញុំ! ខ្ញុំបានសង្គ្រោះលោកវិញហើយឥឡូវនេះ! យើងក៏រួចគ្នា!»

ខ្ញុំសួរដោយសម្លឹងនាងយ៉ាងរីករាយ៖

«នាងសង្គ្រោះខ្ញុំដោយរបៀបណា!?»

នាងរារែក ភ្នែកពួកយើងប្រទាក់។ ខ្ញុំចែចង់នាងបន្ថែម៖

«សង្គ្រោះយ៉ាងម៉េច? បើពេលឥឡូវនេះ ចិត្តរបស់ខ្ញុំនៅជាប់ក្នុងចំណងនៅឡើយហ្នឹង?»

Biancaស្រទន់សម្លឹងមុខខ្ញុំ។ ដង្ហើមនាង ក្លិននាងបញ្ជាក់ថានាងត្រូវការស្តាប់ការពិតពីបេះដូងនេះ។

«ខ្ញុំផ្លោះគ្រោះថ្នាក់មក នាងឱ្យខ្ញុំទៅវិញទាំងបែបនេះ?»

នាងធ្វើមុខកម្សត់។ យើងទើបតែចួបគ្នា តែស្នេហានេះបានប្រទាក់ដឹងឡើងដោយញាណ។

«ហើយខ្ញុំនឹកនាងយ៉ាងនេះ! តើទៅវិញកើតដែរ?»

ខ្ញុំថាបន្តបន្ទាប់ ដោយផ្តោតមើលនាងពីលើដល់ក្រោមយ៉ាងរំភើបហោះហើរ។

ស្រាប់តែត្រចៀកខ្ញុំឮនាងបង្អើបមកថា៖

«ទៅសិនទៅណា! យប់នេះខ្ញុំនឹងចេញទៅក្នុងព្រៃ រកលោក»

ខ្ញុំមិចភ្នែកសម្លឹងភាពស្មោះត្រង់យ៉ាងច្បាស់លាស់នៅក្នុងកែវភ្នែកអង្វររបស់នាង។ នាងនឹង.....ទៅរក....ខ្ញុំ?

«ទៅរកខ្ញុំមែនទេ?» ខ្ញុំស្រាប់តែសួរបញ្ជាក់យ៉ាងរំជួលចិត្ត។ មានអារម្មណ៍ថា យើងមានចិត្តចង់ដូចគ្នា ដែលនាំខ្ញុំមកទីនេះតាំងពីដំបូងហើយនាំនាងមិនឱ្យគេងឱ្យនៅរង់ចាំខ្ញុំ។

មានអ្វីមួយប្រាប់ខ្ញុំថា នេះជាការពិតស្នេហាកំពុងកើតមាន។ ខ្ញុំមិនដឹងថាហេតុអ្វីទេ ប៉ុន្តែខ្ញុំជឿជាក់លើនាង។

ខ្ញុំប្រហែលជាមិនគួរទេប្រថុយយ៉ាងនេះ ឯនាងក៏មិនគួរទុកចិត្តខ្ញុំដែរ។ យើងនៅសងខាងនៃហានីភ័យ។ រវាងយើង.....មិនអាចជាសម្ព័ន្ធមិត្តបានទេ។ ប៉ុន្តែអ្វីដែលជាការពិតគឺយើងកំពុងឈរនៅទីនេះ ទល់មុខគ្នា និយាយភាសា ធ្វើមើលតែស្គាល់គ្នាមក១០០០ឆ្នាំហើយ។

ខ្ញុំនៅសុខៗមកឈរក្នុងផ្ទះរបស់នាងទាំងកណ្តាលអធ្រាត្រ។

«ចាស» នាងបញ្ជាក់។

ខ្ញុំញញឹមដោយមិនចាកចេញ ថែមបោះជំហានទៅរឹតតែជិតនាង។ ភ្នែកយើងនៅក្នុងកម្រិតត្រជាក់ស្រែបជះរស្មីស្រទោស្រទន់រកគ្នា ចិត្តយើងដូចគ្នា.....នាងកំពុងព្យាយាមកាន់បង្កាន់ដៃយ៉ាងមាំ ហាក់ដូចជាតស៊ូនឹងអ្វីមួយក្នុងជម្រៅចិត្តនាងដែលកំពុងលាក់លៀម។

បបូរមាត់ខាងក្រោមរបស់នាងញាប់ញ័រ ខ្ញុំអាចធុំក្លិនបំណងប្រាថ្នាពីក្នុងខ្លួននាង។ នាងមានស្នេហានិងតណ្ហា។ នាងចុះចាញ់ហើយនាងកើតទុក្ខព្រួយ។ កម្ដៅនៃរាងកាយរបស់នាងឆ្លើយតបនឹងបេះដូងរបស់ខ្ញុំ។ នាងពិតជាគួរឱ្យចង់ថៃទាំណាស់។

ខ្ញុំចង់ថ្នមគ្រប់ផ្នែកនៃរាងកាយរបស់នាង ឱ្យនាងសុខសាន្តលែងមានទុក្ខកង្វល់អ្វី។

មើលទៅកាន់កែវភ្នែកស្រងូតៗរបស់នាង ខ្ញុំខ្សឹបឡើងថា៖

«ដឹងទេថា.....ហេតុអ្វីបានជាបងមក? ព្រោះយើងដូចគ្នា! អូនចង់ចេញទៅរកបងនៅក្នុងព្រៃយប់នេះព្រោះបេះដូងនិងរាងកាយយើងបានជំពាក់គ្នា។ យើងដឹងថា យើងជារបស់គ្នា!»

នាងនៅស្ងៀមសម្លឹងតែខ្ញុំ។

ខ្ញុំលើកម្រាមប៉ះមុខនាង។

«ខ្ញុំខុសពីមនុស្សទាំងនេះ ទទួលយកអូន ប៉ុន្តែអូនមិនមែនជាអម្បូរពួកគេទេ! ពួកគេកំពុងប្រើគ្រប់មធ្យោបាយបង្ហាញថានេះ ទង្វើនៃក្ដីមេត្តារបស់ពួកគេប៉ុណ្ណោះ។ គ្មានអ្វីទៀតទេ។ បងវិញ បងចង់រក្សាអូនពេញមួយជាតិនេះ!»

នាងរលីងរលោង។

ខ្ញុំពិតណាស់ មានបំណងប្រាថ្នាតាមការពារនាងនិងចង់បង្ហាញពិភពលោកថា នាងមិននៅម្នាក់ឯងទេ។ យ៉ាងហោចណាស់ ខ្ញុំមកដល់ហើយ ចាប់ពីយប់នេះតទៅ......។

ខ្ញុំចាប់នាងដោយចង្កេះ ហើយទាញនាងមកក្បែរខ្ញុំ។

ដំបូងខ្ញុំរំពឹងថានាងនឹងរុញខ្ញុំចេញ ប្រកែក ព្រោះយើងទើបចួបគ្នាពីរដង ប៉ុន្តែផ្ទុយទៅវិញ នាងបែរជាដួលក្នុងដៃរបស់ខ្ញុំយ៉ាងគួរឱ្យភ្ញាក់ផ្អើល។

នាងមានដង្ហើមតឹងឡើងៗពេលខ្ញុំទាញនាងឱ្យកាន់តែជិត។ ឥឡូវនេះក្បាលសុដន់របស់នាងកំពុងសង្កត់មកលើទ្រូងរបស់ខ្ញុំ។ តម្រូវការចង់មាន បបូរមាត់របស់ខ្ញុំលើប្រាណនាងគឺឡើងហួសកម្រិតស្មានដល់ ប៉ុន្តែខ្ញុំអាចសង្កត់ចិត្តរង់ចាំបាន។

ក្ដីអំណត់បានបង្រៀនខ្ញុំឱ្យចេះរង់ចាំ តាំងពីខ្ញុំបានឃើញនាងជាលើកដំបូង។ ស្បែករបស់នាងក្ដៅនិងជះក្លិនផ្អែម សូម្បីតែបាំងដោយអាវយឺតមួយនោះ។

នាងសម្លឹងមកខ្ញុំ។

ភ្នែកពណ៌ខៀវទាំងទ្វេ រេមកប៉ះកន្លែងណាមួយនៅក្នុងខ្លួនខ្ញុំ ភ្ញោចចិត្តក្លាហាន មេត្តា និងទន់ភ្លន់ ដែលខ្ញុំមិនធ្លាប់ដឹងថាមានបង្កប់ក្នុងរាងកាយបិសាចដ៏ធំនេះឡើយ។

ខ្ញុំចង់រក្សាភ្នែកពណ៌ខៀវទាំងពីរឱ្យមានសុវត្ថិភាពជារៀងរហូតនិងសម្លឹងខ្ញុំបែបនេះ.....ខ្ញុំចង់លង់ជីវិតនេះទៅក្នុងការសម្លឹងរបស់នាង។

ខ្ញុំដកដង្ហើមមិនចង់ចេញទេពេលទទួលអារម្មណ៍ថាកំពុងធ្វើអ្វីមួយខុសៗ។

ស្ដេចបិសាចមិនអាចរួមរស់ជាមួយមនុស្សធម្មតាបានឡើយ។ ខ្ញុំបានជាប់ជំពាក់អម្រែកនៃតំណរត្រកូល ឯការស្វែងរកបិសាចជញ្ជក់ឈាមស្រីដែលសក្ដិសមនិងយកនាងមកធ្វើឱ្យជាមហាក្សត្រី។

ប៉ុន្ដែការរួមរស់ជាមួយមនុស្ស?

ខ្ញុំទាញខ្លួនជាបិសាចមកវិញ ហើយព្រមានខ្លួនខ្ញុំថា «ព្រះអង្គ! ទ្រង់មិនចង់រួមរស់ជាមួយនាងទេ! ព្រះអង្គ គ្រាន់តែចង់ច្របាច់យកខួរក្បាលនាងចេញមក ជញ្ជក់ឈាមនាង...ប៉ុន្ដែ....របៀបដែលនាងកំពុងមើលមកខ្ញុំ ប្រាប់ខ្ញុំថានាងកំពុងមានចិត្តដូចគ្នា.....គឺស្នេហាមិនសក្ដិសមមួយ! បើមិនដូច្នោះទេ នាងក៏មិននៅទីនេះដែរ ក្នុងរង្វង់ដៃនេះ....នាងប្រាកដជារុញខ្ញុំចេញ! ផ្ទុយទៅវិញកែវភ្នែករបស់នាងកំពុងប្រាប់ខ្ញុំថា នាងកំពុងរង់ចាំខ្ញុំថើបនាង។ នាងនឹងមិនបដិសេធឡើយ នាងចង់ធ្វើជាស្រ្ដីធម្មតាដែលចុះចូល។

«Bianca...» ខ្ញុំខ្សឹបឈ្មោះនាងពេលយើងសម្លឹងមើលគ្នាទៅក្នុងប្រស្រីភ្នែក។

បបូរមាត់របស់នាងបានបែកបង្ហើបចេញពីគ្នាហើយ។ នាងមិនបានគ្រប់គ្រងខ្លួននាងបានទៀតទេ។

នាងស្រលាញ់ខ្ញុំ ហេតុអ្វីខ្ញុំបំផ្លាញនាង? ខ្ញុំគួរតែឱ្យនាងទៅ។ ខ្ញុំគួរតែផ្ដោតលើអ្វីសំខាន់នៃវង្សត្រកូល ដែលត្រូវធ្វើបន្តវេន ងាកក្រោយ ហើយបំភ្លេចនាង។

តែខ្ញុំដឹងថា.....ខ្ញុំមិនអាច។

ខ្ញុំគិតផ្សេងធ្វើផ្សឹង ហើយឈ្ងោកទៅភ្លក់បបូរមាត់ដ៏ផ្អែមល្ហែមរបស់នាង។

បេះដូងខ្ញុំ បានឮសំឡេងថ្ងូររបស់នាងដោយក្ដីរំភើប។

មាត់របស់ខ្ញុំគាំងនឹងប្រាណនាង ដូចទឹកសមុទ្របុកច្រាំង សំងំទាមទារយកគ្រប់យ៉ាង ហើយនាងត្រូវផ្ដល់មកឱ្យខ្ញុំទាំងអស់។